ទស្សនាវដ្ដី លេខ ១

# ពុទ្ធិកវិទ្យាល័យ



ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦

ភ្នំពេញ

ចាងហ្វាង. បណ្ណាធិការ. ...

1956
124
ROYAUME DU CAMBODGE
REGIE
DEPOT LEGAL
124 ២

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ . . . . . . | វិចារណកថា | ទំព័រ | ១ |
| ផេង-ស្រីវ . . . . . . . | មនុស្សថ្ងៃថ្ងូរ | ,, | ៤ |
| ព្រះមហាសុខ . . . . . | ពុទ្ធទស្សនៈ | ,, | ៦ |
| លោកកឹយ-ប៊ុក . . . . . | ទៅស្នងទន្សាយធ្វើដំណើរ | | |
| | ពាក្យដំរីញាតិកពលោក | ,, | ៩ |
| ភិក្ខុ ស៊ឹម-សុទ្ធ . . . . . | ដំបូន្មាន | ,, | ១៦ |
| ម. បុស្រី . . . . . . . . | និទានព្រះសុនរសមុទ្រគ្រូរ | ,, | ១៨ |
| . . . . . . | បក្ខណ្ណក | ,, | ២១ |
| . . . . . . | ប្រវត្តិក្មេងកំព្រា | ,, | ២៣ |
| លោកសួន-សុវិន . . . . | បណ្ណកុមារ | ,, | ២៦ |


# ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១.៣៛០០ |

# អ្នកទទួលឲ្យជាវ


សូមផ្ញើបំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# វិចារណកថា

## កំណើតថ្មីនឹងការផ្លាស់រូបរាងនៃទស្សនាវដ្ដីនេះ

តាំងពីប្រាំមួយឆ្នាំកន្លងមកហើយ ប្រទេសកម្ពុជា មានបើកសមាគមមួយ ក្នុងនាមនៃមិត្តសាលាបាលី ដែលមានគ្រោងការសំខាន់បំផុត ចំពោះការលើកតំកើងសាសនានិងអក្សរសាស្ត្រ និងការអប់រំសមណនិស្សិត ឲ្យចេញទៅសិក្សានៅបរទេស កិច្ចការនៃសមាគមនេះ ក៏បានដឿនដំណើរទៅមុខជាលំដាប់ហូរហែរមកដែរ ។ មិនតែប៉ុណ្ណោះ គណៈកម្មការនាយក នៃសមាគមមិត្តសាលាបាលី ក៏បានមូលមតិគ្នាបង្កើតការបោះពុម្ពផ្សាយនូវទស្សនាវដ្ដីមួយច្បាប់ មានឈ្មោះថាទស្សនាវដ្ដីមិត្តសាលាបាលី ជាសំឡេងនៃសមាគម

ទស្សនាវដ្ដីមិត្តសាលាបាលីបានកើតឡើងពីឆ្នាំ ១៩៤៩ ដែលមានលោក ចាប-ពិន ជាប្រធាននិងបណ្ណាធិការ, លោក ជាវីរៈជនមួយរូបដែលមានសេចក្ដីព្យាយាមអង់អាចនិងអត់ធន់ក្នុងករណីយផ្សេង ៗ ដើម្បីនឹងប្រឹងផ្សាយនូវសំឡេង និងឥទ្ធិពល របស់ព្រះពុទ្ធសាសនា ដែលជាសាសនាប្រចាំរដ្ឋយើង ។

កំណើតដំបូងនេះក៏កើតឡើងដោយកម្លាំងយ៉ាងទន់ខ្សោយបំផុត ព្រោះពេលនោះអ្នកអាន ភាគច្រើនពុំបានដឹងដល់ និងពុំបានយកចិត្តទុកដាក់ ដោយពុំយល់អត្ថរស និង ខ្លឹមសារនៃទស្សនា-

វដ្ដីនោះ; ទោះបីដូចម្ដេចក៏ដោយគណៈកម្មការទស្សនាវដ្ដីក្នុងពេលនោះ ស៊ូប្ដូរក្នុងការណ៍នោះយ៉ាងអស្ចារ្យ ដោយបានដាក់ ឲ្យសមាជិកទាំងឡាយជួយផាវយកទៅអានតាមសទ្ធា, តែទោះបីដូចម្ដេចក៏ដោយ យើងធ្លាប់បានដឹងខ្លះមកហើយថា "អ្នកកាន់ព្រះពុទ្ធសាស-នាក្នុងរដ្ឋយើងនេះ មានសភាពមិនខុសគ្នា ពីទឹកជោរ-នាចនៃមហាសមុទ្រនោះឡើយ, ក្នុងពេលដែលមានគេដាស់តឿនក្រើនរំលឹកថានេះជាបុណ្យហើយមានប្រយោជន៍ដល់សតិបញ្ញា យើងក៏បបួលគ្នាស្រាក់ស្រាំប្រឹងជាវច្រើនគ្នាភ្លាម តែដល់ពេលត្រូវបង់ប្រាក់សម្រាប់ថ្លៃនៃទស្សនាវដ្ដីនេះ ក៏ច្រើនតែរុញរាហើយត្អូញត្អែថាគ្មាន ចាំទៅថ្ងៃក្រោយសិនទៅ ហើយបើបែរជាគណៈកម្មការធ្វើសំបុត្រទារប្រាក់ ច្រើនលើកស្រាប់តែមានពាក្យបន្ទោសថា បុណ្យទានស្រេចតែចិត្តគេ ចង់ធ្វើក៏បានមិនចង់ធ្វើក៏បាន ហើយទៅជាខឹងឈប់ជាវតទៅទៀត រួចបែរជាបន្ទោសថាទស្សនាវដ្ដីនេះ មិនល្អមិនមានខ្លឹមសារមិនមានប្រយោជន៍អ្វីប៉ុន្មាន បើទុកប្រាក់ស៊ីចាយប្រហែលជា សប្បាយចិត្តជាង ។

ឱ! មិត្តអ្នកអាន ជាទីគោរពរបស់ខ្ញុំទាំងឡាយ សូមកុំយល់បែបនេះឲ្យសោះបើសិនណា ជាមានចិត្តស្មោះចំពោះព្រះពុទ្ធសាសនាមែន ៗ នោះ ៗ ដោយការយល់ខុសបែបនេះហើយទើបទស្សនាវដ្ដីមិត្តសាលាបាលី ដែលកើតឡើងពីឆ្នាំ១៩៤៩ ក៏ត្រូវរលត់បាត់ជីវិតនៅឆ្នាំ១៩៥២មុន ។

លុះមកដល់ឆ្នាំ១៩៥៤ ខ្ញុំឯងក៏ស្ម័គ្រចិត្តទទួលភារៈដ៏មានទម្ងន់នេះ ល្បងមើលដោយការអាណិតអាសូរ ដល់ដំណើរការរអាក់រអួលនៃទស្សនាវដ្ដីនេះ ។

តែលោកអើយ! នៅឆ្នាំដំបូងនេះគួរឲ្យខ្ញុំ សប្បាយចិត្តណាស់ ដោយឃើញមិត្ត អ្នកអានមានចំនួនច្រើន លើសជាង សៀវភៅ ដែលខ្ញុំត្រូវបេញក្នុងមួយ លើក ៗ ទាំងបព្វជិត ទាំងគ្រហស្ថ, បុរស, ស្ត្រី; ខ្ញុំក៏ខំប្រឹងលៃងគិតទឹកនា ដល់ការនឿយហត់ ពិតមែនតែការ នោះមិនមានប្រយោជន៍អ្វីផ្ទាល់ខ្លួនដល់ ខ្ញុំបន្តិចបន្តួចក៏ដោយ ព្រោះខ្ញុំយល់ថា ជាប្រយោជន៍ដល់សង្គមសាសនាតទៅ អនាគត ៗ ការសប្បាយរីករាយនេះ មិនបាន ទាំងពេញពីរឆ្នាំផង ក៏កើតហេតុ ដូចពីលើកមុន ៗ នោះទៀត ម៉្លោះ ហើយក្នុងឆ្នាំ ១៩៥៥ នេះសមាគមត្រូវ ខាតបង់អស់ចំនួនជាង៩មុឺនរៀលប្រាក់ ទាំងនេះនៅលើមិត្តអ្នកមានរាល់រូបដែល ពុំទាន់បានបង់ ចុះបើមិត្តមិនបង់ថ្លៃជាវ ដូចនេះតើការ សិក្សា របស់សមណៈនិ- ស្សិតយើង ដែលបានចេញទៅបរទេស រូបទៅហើយ នោះនឹង បានអ្វីជា អាហារ រូបករណ៍? ចំពោះសមណៈនិស្សិតដែល ចេញទៅសិក្សានៅពេលមុន ៗ ។

ដោយព្រះរាជហឫទ័យ ដ៏ជ្រះថ្លា របស់សម្ដេចព្រះឧបយុវរាជ ក៏សមណៈ និស្សិតយើងត្រូវបានចេញទៅសិក្សាជា ផ្លូវការចាប់តាំងពីឆ្នាំ ១៩៥៦ នេះតទៅ តែទោះបីយើងបានផ្លូវខ្លះក្នុងការ សិក្សា នេះក៏ដោយ ក៏គង់នៅបារម្ភលើជីវិតនៃ សមាគមនេះដែរ ។

ក្នុងឆ្នាំ ១៩៥៦ នេះទុកដូចជាឆ្នាំ ដែលយើង ខ្ញុំត្រូវ ផ្សង ព្រេងម្ដង ទៀត ដោយឆ្នាំនេះសមាគមមិត្តសាលាបាលី បានប្រែនាមថាសមាគម មិត្តពុទ្ធិក- វិទ្យាល័យ ហើយទស្សនាវដ្ដីនេះទៀត សោតក៏ត្រូវផ្លាស់ឈ្មោះថា ទស្សនា វដ្ដីពុទ្ធិកវិទ្យាល័យ

ទស្សនាវដ្ដីមិត្តសាលាបាលីបាន

តទៅទំព័រទី ១១

# មនុស្សប្លែប្លិវ

មនុស្សក្នុងសាកលលោកតែងស្អប់ខ្ពើមនូវការក្រខ្សត់ តែងខំចៀសវាងចាកការគ្មានយសសក្តិ ព្រោះដឹងច្បាស់ថាវត្ថុទាំងពីរខាងលើនេះបន្ថោកបន្ទាបមនុស្សជាតិ ៗ គេក៏ខំប្រឹងដោយមធ្យោបាយផ្សេង ៗ តាមសមត្ថភាពរៀងខ្លួន ដើម្បីពុះពារនូវឧបសគ្គដែលរាំងមាគ៌ាជាទីដឹកនាំអាត្មាទៅរកសេចក្តីថ្លៃថ្នូរ ៗ

មែនពិត ទ្រព្យសម្បត្តិនិងយសសក្តិ ធ្វើឲ្យមនុស្សមានតម្លៃជាប្រាកដក្នុងលោកបច្ចុប្បន្ននេះ ប្រសិនបើគេចេះប្រើ ៗ ដោយអាស្រ័យទ្រព្យសម្បត្តិ គេអាចទិញអាហារភោជនសម្រាប់លៀងជីវិត ទិញសម្លៀកបំពាក់សម្រាប់បិទបាំងរាងកាយ ដើម្បីការពារនឹងភាពអាក្រាត សីតុណ្ហភាព ព្រមទាំងមូសសុចជាអាទិ ៗ មិនតែប៉ុណ្ណោះ គេតាក់តែងលំអរាងកាយដោយអលង្ការ ក៏អាស្រ័យនឹងទ្រព្យនេះដែរ ហើយគេហស្ថានធំ ៗ ទាំងឡាយដែលកសាងកើតឡើងបាន ក៏ដោយសារទ្រព្យសម្បត្តិនេះទៀត ៗល ៗ

កាលណាទ្រព្យសម្បត្តិមានសព្វគ្រប់ហើយ សេចក្តីសុខក៏កើតមានដោយសារ វៀរលែងតែកុំយកវាធ្វើជាម្ចាស់ នោះទ្រព្យនឹងក្លាយទៅអសិរពិស ៗ

បំណែកយសសក្តិធ្វើឲ្យមនុស្សមានអំណាច ឲ្យមានកេរ្តិ៍ឈ្មោះ មានគេគោរពកោតក្រែងច្រើន ក៏ដោយសារយសសក្តិនេះឯង ៗ គឺយសសក្តិនេះហើយ ដែលមនុស្សលោកតែង

ប្រាថ្នាជាយ៉ាងក្រៃលែង ។

ដូច្នេះដើម្បីឲ្យបានថ្លៃថ្នូរ គេខំប្រឹងបំពេញមុខការ រៀនខ្លួន ឥតឈប់ឈរ ។ ជនពួកខ្លះស្វែងរកដីឲ្យបានច្រើនកន្លែងទុកជាកម្មសិទ្ធិ ដ្បិតមានដីច្រើនកន្លែង ទោះជាប្រភេទណាក៏ដោយ អាចផ្ដល់ប្រយោជន៍ឲ្យដល់អ្នកម្ចាស់កម្មសិទ្ធិ ។ គេទុកដីប្រើខាងកសិកម្មក៏បាន ទុកប្រើសម្រាប់សង់គេហដ្ឋានក៏បាន ។ ជនពួកខ្លះទៀតស្វែងខាងផ្លូវពាណិជកម្មផ្សេង ៗ មានដួញស្រូវអង្ករជាអាទិ ដែលជាគ្រឿងបង្ហូរនូវកោតទ្រព្យ ហើយដែលជាមេសេដ្ឋកិច្ចនៃប្រជាជាតិនិមួយ ៗ ផង ។ ជនក្រុមផ្សេងដទៃខំរក រៀនវិជ្ជាទាំងឡាយមាន អក្សរសាស្ត្រ និង វិទ្យាសាស្ត្រ ជាដើម ព្រោះតាមមធ្យោបាយនេះ គេក៏អាចទៅជាមនុស្សថ្លៃថ្នូរបាន ជួនកាលប្រសើរ លើស អ្នក មាន ទ្រព្យ សម្បត្តិផង ។

ដោយយល់ច្បាស់ដូច្នេះ មនុស្សនានា មិនថាជាតិណាឬភាសាណាតែងខំប្រពារទៅរក ។ មនុស្សទាំងអស់ដែលខំស៊ុះស្វារទៅរកភាពថ្លៃថ្នូរ នឹងបានសម្រេចគ្រប់ៗគ្នាឬដូចម្ដេច? រឿងនេះមិនប្រាកដទេឡើយ ។ ខ្លះក៏បានដល់នូវទីដៅ ខ្លះបានត្រឹមពាក់កណ្ដាល ខ្លះទៀតត្រូវឧបស័គ្គពាំង ហើយរបូតដៃរបូតជើងធ្លាក់មកវិញ ។

ប៉ុន្តែសេចក្ដីត្រូវការឥតព្រំដែនទៅរកភាពថ្លៃថ្នូរនេះជាការចាំបាច់ នៃសាមញ្ញបុថុជ្ជនទេ ដែលពេញចិត្តតែនឹងបំប៉ននូវចំណង់មិនចេះពេញរបស់ខ្លួន ។ បើគេដើរតាមផ្លូវនេះហើយមិនសម្រេច គេគេចវាងទៅ ដើរតាមផ្លូវខាងណោះទៀត គេមានសេចក្ដីសង្ឃឹមជានិច្ច ព្រោះមានភាសិតបារាំងមួយថា: "បើ-

តទៅទំព័រទី ១២



## ពុទ្ធទស្សនៈ (ត ពីឆ្នាំ១៩៥៥)

ទើបលះបង់ការស្លៀកដណ្ដប់ចោលចេញ ហើយបានឈ្មោះថា "ទិគម្ពរ" ប្រែថា "ស្លៀកឬដណ្ដប់មេឃ" ឬពួកយើងហៅថា "បកសំបកឬបកស្បែក" ។ មហាវីរៈជាសាស្ដារបស់ពួកនិគ្រន្ថ កើតមុនព្រះពុទ្ធជាម្ចាស់របស់យើងជាច្រើនឆ្នាំ ។ ដូចនោះហេតុដែលគួរជឿថា: ព្រះពុទ្ធជាម្ចាស់ទ្រង់បានជ្រាបលទ្ធិនោះ ហើយទឹងកិច្ចការរបស់ពួកនិគ្រន្ថតាំងអំពីមុន ដែលស្ដេចចេញបួសម៉្លេះ ។

កាលបើខ្ញុំបាន ពោលមកដល់គោលនេះហើយ នៅមានអ្នកខ្លះចង់សួរចង់ដឹងតទៅទៀតថា: បើដូច្នោះព្រះពុទ្ធជាម្ចាស់ នៅមានសល់អ្វីសម្រាប់ត្រាស់ដឹងតទៅទៀត ? ឆ្លើយថា:

នៅមានច្រើនណាស់ បើទុកជាយើងដឹងថា: ធម៌ដែលប្រាកដមាននៅក្នុងព្រះពុទ្ធសាសនា ក៏មានប្រាកដនៅក្នុងសាសនាព្រាហ្មណ៍ នឹងលទ្ធិរបស់និគ្រន្ថដោយច្រើន, អត្ថន័យនេះនឹងចាត់ថា: ជាសេចក្តីស្នាវៃនៃសាសនធម៌របស់ព្រះពុទ្ធជាម្ចាស់នោះពុំបានឡើយ

ន័យនេះប្រៀបដូចជាទព្វសម្ភារៈដែលសម្រាប់ប្រកបឬសាងឡើងជារថយន្តព្រោះវិស្វករ(ជាង)ដែលអាចសាងរថយន្តឡើងជាច្រើនបែប ច្រើនយ៉ាងបាន ក៏ដោយសារតែសេចក្តីអង់អាចរបស់ខ្លួន ៗ

សេចក្តីពិត រួមខ្លីមកក៏នៅតែឈ្មោះថា: រថយន្ត "ស៊ីត្រូអែន-រឺណូត៍ហ្វ័រ ,, ដែលបរិស័ទវិស្វករនោះ ៗ ប៉ុណ្ណោះសាងបាន, វិស្វករធ្វើរថយន្តក៏មានច្រើនហេតុដូចម្តេច ក៏សាងរថយន្តឡើង មិនបានជាទីនិយម-ពប់អានដូចរថយន្ត "ស៊ីត្រូអែន ,, ឬ "ទោចក្រយាន ប៉ឺហ្សូ ,, នោះផង? សេចក្តីនេះមានឧបមាដូចម្តេច? ទង់ផ្លូវសាសនាក៏ដូច្នោះ, ៗ ធម៌ល្អគេតែងនិយមថាល្អទាំងអស់គ្នា ៗ ដូចជាទព្វសម្ភារៈមាន តែមិនមានសាស្តាណាអាចផ្សំផ្គុំនូវទព្វសម្ភារៈនោះ ៗ ឲ្យកើតឡើងជាសាសនាដែលគួរជ្រះថ្លា គួរឲ្យជឿ គួរឲ្យពប់អាន នឹងធ្វើអ្នកដែលជឿនោះ ៗ ឲ្យសប្បាយរីករាយចិត្តដូចជាព្រះពុទ្ធម្ចាស់យើង ដែលទ្រង់បានប្រតិស្ឋានឡើងនោះឡើយៗ ន័យទាំងនេះគង់ឃើញថាសាស្តាដទៃសូម្បីបានបេះដឹងនូវធម៌ផ្សេង ៗ មកហើយ តែគង់នៅខ្វះខាតសេចក្តីសំខាន់អ្វី នៅក្នុងនោះ បានជាធ្វើពាក្យប្រៀនប្រដៅរបស់សាស្តានោះ ៗ ឲ្យសាបរលាយទៅបាន មិនបានល្អដល់ទីបំផុត ៗ សាស្តានឹងបាមោក្ខទាំងឡាយ ក៏នាំ

គ្នាខ្វល់ខ្វាយរកវត្ថុដែលខ្វះខាតនោះ ៗ គ្រប់គ្នា តែមិនមានអ្នកណាមួយបាន ជួបប្រទះឡើយ ។

ឯព្រះពុទ្ធជាម្ចាស់ ព្រះអង្គបាន ជួបប្រទះនូវវត្ថុដែលខ្វះខាតនោះ ៗ លុះ ជួបហើយទើបបានព្រះនាមថា:

សម្មាសម្ពុទ្ធ ជាអ្នកត្រាស់ដឹង ដោយព្រះអង្គឯង, គឺខ្លួនព្រះអង្គឯង ឲ្យត្រាស់ដឹង, ដាស់តឿនព្រះអង្គឯងឲ្យ ភ្ញាក់រឭកឡើង

## ការត្រាស់ដឹង

ការត្រាស់ដឹងរបស់ព្រះពុទ្ធនោះមិន មែនបានមកដោយឆូ ៗ ងាយ ៗ ឡើយ រាប់តាំងអំពីព្រះអង្គស្តេចចេញបព្វជ្ជា កាលព្រះជន្មាយុបាន ២៩ វស្សា ដល់ព្រះ ជន្មាយុ ៣៥ វស្សា ទើបបានត្រាស់ដឹង ក្នុងរវាង ៦ ឆ្នាំនោះ ព្រះអង្គទ្រង់ព្យា យាមស្វែងរក ផ្លូវដែលអាចឲ្យសម្រេច តាមព្រះរាជបំណង ដោយវិរិយភាពដ៏ ខ្លាំងក្លា រកបុគ្គលដទៃឲ្យស្មើនឹងព្រះ អង្គគ្មានឡើយ នេះសំដែងឲ្យឃើញថា: ព្រះអង្គមានព្រះរាជហឫទ័យខ្វះខ្វែងក្នុងផ្លូវ ដែលរកសេចក្តីពិតយ៉ាងប្រសើរ គឺសេចក្តីពិតមិនមានបុគ្គលណាទឹងចាក់ធ្លុះបាន ឡើយ ៗ ដោយមានព្រះរាជបំណង យាងទៅសិក្សាក្នុងសំណាក់គ្រូអាចារ្យ ដែលមហាជនក្នុងសម័យនោះ រាប់អាន ថា: ជាកំពូលដ៏លើស តែនៅមិនល្មម នឹងព្រះហឫទ័យ; ព្រោះលទ្ធិរបស់អាចា រ្យនោះ ៗ មិនបានកាត់ផ្តាច់នូវកាមសុខ ល្លិកានុយោគ គឺការជំពាក់ក្នុងកាម ដូច បានអធិប្បាយរួចមកហើយ ។ ព្រះអង្គ ស្តេចចេញ អំពីសំណាក់អាចារ្យហើយ ទៅប្រថាប់នៅដំបន់ឧរុវេលា ក្នុងដែន មគធៈដែលជាទីរមណីយស្ថាន មាន ផ្ការទឹកហូរនៅជិត ៗ ហើយមានដើម ឈើធំជាទីអាស្រ័យម្លប់បាន ស្រួល

តទៅទំព័រទី ១៤



## បៅស្នែងទន្សាយធ្វើដំណើរជុំវិញពិភពលោក

លំដាប់តមក ១៩៤១, មានការចលនាស្វ័យរាជ ហើយលោកក៏បានថ្លែងសុន្ទរកថានៅច្រើនកន្លែង ហើយរាជការក៏បានចាប់លោកអំពីរឿងនាំចលាចលក្នុងស្រុក ៗ ក្រៅពីលោកមានការចាប់ឃុំឃាំងមនុស្សឯទៀតជាច្រើនប្រហែល ៣០.០០០ នាក់, អំពីរឿងចូលទៅប្រួប្រមួលនឹងការចលាចលមិនព្រមធ្វើសហការជាមួយរដ្ឋាភិបាល ៗ បិតាលោកនឹងលោក ត្រូវទទួលទោសប្រាំមួយខែ, បិតាលោក, រាជការចោទថាជាពួកក្រុមប្រព្រឹត្ត ល្មើសនឹងច្បាប់ (ពួកក្រុមសមាជ:), ចំណែកឯលោក, គេចោទប្រកាន់ថា លោកបោះបាចវិតប័ណ្ណនាំបះបោរ ៗ តែបន្តិចទៀតមិនដឹងដោយហេតុយ៉ាងណា, បានជា

លោកនេហ៍រូរួចពីពន្ធនាគារ ហើយលោកក៏បានអញ្ជើញទៅជួបនឹងលោកមហាត្មៈគន្ធី នៅទីក្រុងអល្លាហាបាដ, តែលោកមហាត្មៈគន្ធី រាជការបានចាប់យកទៅឃុំឃាំងនៅគុកសប្បារម៉ាតី ។ ឆ្នាំ ១៩២១, លោកនេហ៍រូគេបានយកទៅឃុំឃាំងនៅពន្ធនាគារ លុកនូវៈ, ដល់មកថ្ងៃទី ៣១ មករា ១៩២៣, ទើបរួចពីគុក ។

ពីឆ្នាំ ១៩២៣ មកដល់ចុងឆ្នាំ ១៩២៥, លោកមានកិច្ចដោះស្រាយបញ្ហាខាងគ្រួសារដោយទទួលអំពីរឿងប្រាក់កាស, តែក្នុងពេលនោះលោកបានទទួលមុខការខុសត្រូវសំខាន់ៗ នាសមាជប្រទេសឥណ្ឌៀ ។ ដល់មកវស្សានរដូវ១៩២៣, គណៈកម្មាធិការកណ្ដាលនៃសមាជបានមកប្រជុំគ្នានៅទីក្រុងបុំបៃ ។ ពេលនោះលោកដាសជាអធិបតីនៃគណៈកម្មាធិការនេះក៏សូមលាងារឈប់ពីតំណែង ។ សមាជបានជ្រើសតាំងលោក ឱ.ទ. អង់សារី ជាប្រធាន ; ក្នុងពេលនោះលោកនេហ៍រូ ចូលទៅធ្វើការខាងលេខាធិការនៃសមាជ ។ គណៈកម្មាធិការសមាជបានមកប្រជុំនៅទីក្រុងនាគបុរៈ ។ ដល់មកខែធ្នូ ១៩២៣, ការប្រជុំអនុសំវច្ឆរៈនៃសមាជ ត្រូវធ្វើនៅទីក្រុងកុក្កូណាដា, ក្នុងភាគខាងត្បូងក្រោមអធិបតីភាពលោកមៅល៉ាណា - ម៉ូហាម៉េត - អាលី ។

លោកមៅល៉ាណា - ម៉ូហាម៉េត-អាលីបានកាន់កាប់សមាជតមក, ដល់វស្សានរដូវ គ.ស. ១៩២៨, លោកក៏អញ្ជើញទៅកាន់ទ្វីបអឺរ៉ុប ។ ដល់ក្រោយមក, លោកនេហ៍រូបានទៅជួបសន្ទនាការនឹងលោកម៉ូហាម៉េត - អាលីនៅសមាជឡាហ៊ូរ ( ធ្នូ ១៩២៩ ) ។

តទៅទំព័រទី ១៥

## វិបារណៈកថា (ត)

ផុសរូបរាងនឹងឈ្មោះមកជា ទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ កំណើតលើកនេះហាក់ដូចជាត្រូវកសាងជាថ្មីម្ដងទៀត ព្រោះថាយើងខ្ញុំប្រុងនឹងស្ទុះបន្ទន់ទៅ ហើយដោយការខាតបង់ច្រើន ហើយខុសបំណាំជាងសព្វដងរបៀបនេះ ស-មាគមក៏គួរតែបន្ទន់ការចេញផ្សាយសិន ព្រោះក្រែងរលាយដល់អាយុជីវិត នៃសមាគមទៀត ៗ តែដោយមានការឧបត្ថម្ភពីឯកឧត្តមឈួន-ម្ហូលពេជ្រព្រះរាជប្រតិភូប្រចាំខេត្តសៀមរាប យើងខ្ញុំក៏ត្រូវតែស៊ូកង់ការនេះម្ដងទៀត

ដើម្បីជីវិតនឹងការថ្ងៃថ្នូសម្រាប់សមាគមនឹងទស្សនាវដ្ដីលើកនេះ ខ្ញុំសូមអង្វរចិត្តមិត្តគ្រប់ឋានៈមេត្តាជួយជាវអាននឹងបង់ប្រាក់ ឲ្យបានគ្រប់គ្រាន់តាមកំណត់

តាងនាមសមាគមនឹងគណៈកម្មការទស្សនាវដ្ដីពុទ្ធិកវិទ្យាល័យ ខ្ញុំសូមលើកយកនូវទឹកចិត្តដ៏បរិសុទ្ធជាកុសលជូនចំពោះឯកឧត្តម ដែលមានសទ្ធាជួយទទួលយកចំនួនទស្សនាវដ្ដីច្រើនជាងបីរយច្បាប់ ដើម្បីអ្នកអានភាគច្រើនក្នុងខេត្ត ៗ អំពើដ៏ថ្លៃថ្លានេះទុកដូចជាឯកឧត្តមបានជួយបណ្ដុះនិស្ស័យខេមរជាតិភាគច្រើនដែលមិនទាន់ស្គាល់ឬយល់ដល់ សមត្ថកិច្ចនៃព្រះពុទ្ធសាស-នា ឲ្យស្គាល់ឬយល់ថាក្នុងស្ថានទៀនទៅអនាគតនឹងការដម្រះនូវជនល្ងង់ខ្លៅឲ្យស្គាល់សភាពគុណនឹងទោសដោយពិតប្រាកដ

ករណីយនេះនឹងចាត់ទុកជាកុសលមួយយ៉ាងថ្លៃថ្លា, ខ្ញុំសូមឲ្យឯកឧត្តមនឹងបរិវារ បានសម្រេចតាមគោលបីយ៉ាងនឹងករណីយតទៅអនាគតដោយសុវត្ថិភាព

បណ្ណាធិការ

## មនុស្សថ្លៃថ្នូរ (ត)

ចង់បាន„ តែត្រង់ធ្វើតាមមធ្យោបាយបែបណាជាកុសលឬអកុសល ភាសិតនេះមិនបានប្រាប់ផងឡើយ ។ ម្ល៉ោះហើយ ជនណាដែលបានដល់នូវទីដៅនៃអាត្មាតែងសប្បាយរីករាយ ដោយនឹកមិនភ្លេចទាំងយប់-ថ្ងៃ ថាខ្លួនជាមនុស្សថ្លៃថ្នូរមានកេរ្តិ៍សនាល្អ ។

ចំណែកជនដទៃដែលមិនបានសម្រេចនូវបំណង តើនឹងមានមនោសញ្ចេតនានឹកគិតយ៉ាងណា? ត្រង់នេះហើយជាតួបញ្ហាដ៏ធំ ហើយស្មុគស្មាញដូចជាព្រៃញាតស្បាត ដែលមនុស្សអន់ខ្សោយ ខាងការពិសោធន៍ ព្រមទាំងប្រាសចាកមនោគតិជាកុសល មិនងាយនឹងដោះស្រាយបាន ។

អំពីរឿងនេះ ទើបមានសំនួរកើតឡើង: ហេតុដូចម្ដេចបានជាលោកិយដោះប្រស្នានេះបានដោយលំបាក? លុះដោះមិនបានស្រួលហើយ ខ្លះទៅជាអស់សង្ឃឹម ហើយដាក់ខ្លួនឯងជាមនុសថោកទាប?

សូមអស់លោកក្រឡេកមើលលោកិយសព្វថ្ងៃប្រព្រឹត្តបែបណា? គេនិយមប្រើតែឧបាយកល នឹងបទមាយា គឺថា គេច្រើនប្រតិបត្តិតាមបុរាណភាសិត: "ចិត្តជាទេវទត្ត មាត់ជាទេវតា„ ។ គេធ្វើយ៉ាងណាឲ្យតែបានសម្រេចប្រយោជន៍ផ្ទាល់ខ្លួន រួចគេតាំងដោយខ្លួនឯងថាជាមនុស្សថ្លៃថ្នូរ ។ ចំណែកអ្នកដែលមិនមានសមត្ថភាព ឬមិនមានមធ្យោបាយគ្រប់គ្រាន់ក៏សម្រុតខ្លួនឬក៏ត្រូវគេសម្រុតចុះជា "មនុស្សថោកទាប„ ។ ហើយលោកិយក្រុមនេះ បន្ទោកខ្លួនតាំងពីសរីរកាយរហូតដល់ចិត្តគំនិត ព្រោះតែខ្លួនយល់មិនច្បាស់ ត្រង់ណាហៅ "មនុស្សថ្លៃថ្នូរ„ ។

សូមអស់លោក កុំកាន់ប្រឡំ "មនុស្សថ្លៃថ្នូរ" មិនមែននៅត្រង់សម្ភារៈនិយមទេ ដែលសាកលលោកសព្វថ្ងៃកំពុងប្រកាប់ប្រចាក់ដណ្ដើមគ្នានោះ ៗ មែនពិតយើងមានរូប យើងត្រូវការរូបខាងក្រៅយកមកជារណប រូបខាងក្នុង ដើម្បីជួយគាំពារឲ្យតាំងនៅតាមលំដាប់កាល ប៉ុន្តែតម្លៃបរិសុទ្ធមិនមែននៅត្រង់យើងមានទ្រព្យសម្បត្តិទឹងមានយសសក្តិនោះទេ ៗ មានបុប្ផជាតិជាច្រើនដែលមានផ្ការីកស្គុះស្គាយក្រហមច្រាលឆ្អៅ ហើយស្អិតនៅជាបុប្ផជាតិឥតមានសារៈអ្វីសោះក៏មាន ឧទាហរណ៍ដូចជាផ្កាចារទឹងផ្កាអាចម៍ត្ពិស ៗ

ដូច្នេះ អ្នកខ្សត់ខ្សោយ ដោយធនធានទឹងដោយយសសក្តិ មិនគួរគប្បីដាក់ខ្លួនឲ្យទាបជ្រុលហួសឡើយ ៗ "មនុស្សថ្លៃថ្នូរ" មិនមែននៅត្រង់ "ក្រធនធាន គ្មានយសសក្តិឬមានភោគទ្រព្យមានយសសក្តិនោះទេ" អ្នកក្រមិនចាំបាច់គោរពអ្នកមាន រាស្ត្រមិនចាំបាច់គោរពនាម៉ឺនទេឬ? មិនមែនទេ ៗ មនុស្សមានគុណផ្សេង ៗ គ្នា: ខ្លះមានវ័យច្រើន ខ្លះមានវ័យតិច ខ្លះមានសីល ខ្លះឥតសីល ខ្លះរាស្ត្រ ខ្លះនាម៉ឺន ៗ ឯគារវកិច្ចជាអាការខាងក្រៅដែលគេត្រូវតែធ្វើដើម្បីចៀសវាងកុំឲ្យខ្លួនយើងធ្លាក់ទៅជាមនុស្សបោកទាបនេះឯង ៗ ប៉ុន្តែមិនត្រូវគោរព ដោយដាក់ខ្លួនជាមនុស្សបោកទាបឡើយ ព្រោះគារវកិច្ចជាដំបែរនៃសេចក្តីស្នេហា ជាស៊ីម៉ង់សម្រាប់ផ្សារនូវសេចក្តីប្រេះឆារ ហើយបដិគាហកមិនគប្បីយល់កាន់ថាខ្លួនថ្លៃថ្នូរជាងអ្នកដែលគោរពខ្លួននោះទេ ៗ ការយល់បែបនេះត្រូវធ្លាក់ចុះក្នុងរណ្ដៅមោហាគតិមិទាំងស្រុង ៗ

ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់ទេសនាប្រដៅថា: ដែលគេចាត់ទុកជា "មនុស្ស

ថ្លៃថ្នូរ,, គឺមនុស្សមានអាយុទ្រព្យប្រាំពីរ ប្រការ ( សទ្ធា សីលៈ ហិរិ ឱត្តប្បៈ ចាគៈ សុតៈ បញ្ញា ) ។ សទ្ធា ប្រែថា: ជឿកម្ម នឹងផលនៃកម្ម - សីលៈ មាន កាយនឹងវាចារៀបរយល្អ គឺប្រាសចាក បញ្ចវេរាទាំងប្រាំ ( សីលប្រាំ ) — ហិរិៈ ខ្មាសអៀនអំពើទុច្ចរិត — ឱត្តប្បៈ ក្តៅក្រហាយនឹងអំពើទុច្ចរិត — ចាគៈ លះទ្រព្យធ្វើទាន — សុតៈ ពេញចិត្តត្រងត្រាប់ស្តាប់សំដីសុចរិត — បញ្ញាៈ មានប្រាជ្ញា ។

ផេង - ជ្រើវ

---

## ពុទ្ធទស្សនៈ (ត)

ដល់ការដែលស្តេចនៅដោយស្ងាត់មិនមានបុគ្គលកេក្ខួន ។ កាលបើស្តេចរើសរកកន្លែងបានល្អហើយ ទើបស្តេចខ្នះខ្នែងបំពេញតបៈ ដោយអាការៈផ្សេងៗ ដែលគេនិយមក្នុងសម័យនោះ ថា: "របស់ល្អ" គឺទ្រង់អត់អាហារដរាបដល់ស្គាំងស្គម ដែលហៅតាមភាសាសាមញ្ញថា: "ស្បែកដណ្តប់ឆ្អឹង" ហើយទ្រង់ទរមានព្រះអង្គ ដោយវិធីផ្សេងៗ ។

១— ការអត់អាហារនឹងការទរមានរាងកាយដោយវិធីផ្សេងៗ ដូចពោលមកនោះ ដោយទ្រង់យល់ឃើញថាជា "អត្តកិលមថានុយោគ" គឺការប្រកបឲ្យនឿយហត់ដល់ខ្លួនទទេៗ មិនមែនជាប្រយោជន៍ឡើយ, ព្រោះទុក្ខវេទនានៃរាងកាយច្រើនដូច្នេះ មុខជានឹងត្រឡប់ធ្វើឲ្យចិត្តវង្វេងនឹកដល់សេចក្តីសប្បាយ នឹងសេចក្តីក្តៅក្រហាយ ឬឈឺចាប់, មិនអាចធ្វើចិត្តឲ្យចុះស៊ប់ក្នុងសមាធិ ដែលជាប្រកនៃឈានទាំងពួង ។

(នៅមានត)

## ចៅស្នែងទន្សាយធ្វើដំណើរ (ត)

ក្នុងពេលនោះ លោកនេហ៍រូជាប្រធានសមាជ, លោកបានថ្លែងសុន្ទរកថាមួយជាយ៉ាងក្លោះក្លាយ ។

លំដាប់តមក, លោក នេហ៍រូ បានតស៊ូដើម្បីប្រជាជាតិ ឥណ្ឌៀ មានចាប់ឃុំឃាំងជាច្រើនលើក ជាមួយលោកមហាត្មគន្ធី ។ ពី គ.ស. ១៩៣០ ទៅ គ.ស. ១៩៤៧, គេបានជួបប្រទះនឹងការធ្វើបាតុកម្ម នឹងការចលាចលជាច្រើនដោយសន្តិវិធី ។ បិតាលោកនេហ៍រូ បោះបង់ចោលគណបក្សអភិរក្ស បានចូលទៅរួមជាមួយ ការចលនានេះ ។ គណៈបក្សរួបរួមប្រជាជាតិហិណ្ឌូដែលជាក្រុមនយោបាយសំខាន់ប្រទេសឥណ្ឌៀ បានប្រជុំគ្នាជាច្រើនលើក, តែរាជការអង់គ្លេសបានចាប់មេនាំបះបោរទៅឃុំឃាំងទាំងអស់ ។ លោកនេហ៍រូ បានហាមប្រាមកុំឲ្យប្រជារាស្ត្របង់ពន្ធដារឲ្យពួកអង់គ្លេស, ហើយលោកក៏មិនបង់ដែរ, បានជារាជការអង់គ្លេសបានដកហូតយកសង្ហារិមៈនៃគេហដ្ឋានរបស់លោក នៅទីក្រុងអល្លាហាបាដ ។ បុត្រីរបស់លោកនេហ៍រូ នាមនាង អ៊ីងឌីយារ បានពណ៌នាថា គ្រួសារអ្នកដទៃជាច្រើនបានផុតបំផ្លាញចោលនូវគ្រឿងសំលៀកបំពាក់របស់អង់គ្លេស ហើយ សំដែងមនោសញ្ចេតនារីករាយជាយ៉ាងក្រៃលែង ។

ដល់ គ.ស. ១៩៤៧, ប្រទេសឡាក្រង់ប្រ៊ីតាញ បានចាត់ការឲ្យបោះឆ្នោតជាថ្មីព្រមទទួលឲ្យរដ្ឋាភិបាលកម្មករអង់គ្លេស ។ ក្នុងពេលនោះពួកអ្នកបះបោរទាំងប៉ុន្មាន ក៏នាំគ្នាធ្វើបដិវត្តស្ថាបនានូវរដ្ឋាភិបាលឥណ្ឌៀ ដែលមានលោកនេហ៍រូជាអគ្គសេនាបតី ។

(នៅមានត)

# ជំបូន្មាន

## ពាក្យកាព្យ

នេះពាក្យទំនៀមបុរាណមុន
ទូន្មានពួកជនតទៅមុខ
ឲ្យអស់កូនចៅចងចាំទុក
នឹងបានទីសុខមកជួបជួន ៗ
កុំឲ្យលួចគេវាធ្លាប់ដៃ
កុំឲ្យដេកថ្ងៃវាធ្លាប់ខ្លួន
កុំឲ្យស្ដីញាប់វាធ្លាប់ផ្ទួន
កុំឲ្យថ្នមខ្លួនវាធ្លាប់ខ្ជិល ៗ
កុំឲ្យស្មោកគ្រោកវាថោកការ
កុំឲ្យផឹកស្រាវាដាច់សីល
កុំឲ្យស៊ីច្រើនវាច្រើនខ្ជិល
កុំឲ្យកកិលវាធ្លាប់បុក ៗ
កុំឲ្យស្ទៀមដៃវាធ្លាប់លួន
កុំឧបជ្គន់វាធ្លាប់ស្ទឹក
កុំឲ្យយឺតពេកវាទ្រមឹក

កុំឲ្យឆ្មើងបុកគេស្អប់ខ្លួន ៗ
កុំឲ្យស្រួសពេកវាបែកបាក់
កុំឲ្យថ្នាំងថ្នាក់វាបាត់ស្ងួន
កុំខ្ជិលដោដោកវាថោកខ្លួន
កុំឲ្យវៀះពួនវាបាត់មុខ ៗ
កុំឲ្យម្នះពេកវាបែកមិត្ត
កុំឲ្យទ្រុះស្និទវាបាត់សុខ
កុំឲ្យលើកខ្លួនវាផ្ទួនទុក្ខ
កុំឲ្យបាត់មុខវាអប្រិយ៍ ៗ
កុំឲ្យធ្វើស្នេហ៍វាបែរឃ្លាត
កុំឲ្យទ្រុះញាតិវាបង់ក្ដី
កុំឲ្យហ៊ានហួសអាយុខ្លី
កុំឲ្យជេស្រីវាខូចទ្រព្យ ៗ
កុំឲ្យចង់ពេកវារែងឃ្លាត
កុំឲ្យប្រមាទវាខូចឆាប់

កុំឲ្យស្ទួរពេកវាគន់គាប់
កុំឲ្យប្រញាប់វាបែរយូរ ៗ
កុំឲ្យព្រះហើនវាច្រើនទុក្ខ
កុំឲ្យប្រង៉ុកវាបាត់គូ
កុំឲ្យចង់តឹងវាបានធូរ
កុំឲ្យមុខមូវាខានគាប់ ៗ
កុំឲ្យស៊ីច្រើនវាបែកពោះ
កុំឲ្យលេះលោះវាខូចទ្រព្យ
កុំឲ្យខុសរឿយវាអកញ្ញ
កុំឲ្យលេលាប់វាផ្លាប់ចិត្ត ៗ
បើនឹងចេះអស់ឲ្យគេកោត
បើនឹងឆោតឲ្យគេអាណិត
បើម្លៃនឹងហ៊ានឲ្យមានចិត្ត
បើម្លៃនឹងគិតឲ្យបានការ ៗ
បើម្លៃនឹងកាចឲ្យពេញវង្ស
បើម្លៃនឹងល្ងង់ឲ្យផុតថា
បើម្លៃនឹងខូចឲ្យចេះការ
បើម្លៃគេថាឲ្យហួសខ្នាត ៗ
ឲ្យរៀនអត់ធុនពាក្យជូនតា

ឲ្យរៀនវិជ្ជាការសិល្បសាស្ត្រ
ឲ្យរៀនចិត្តល្អកុំប្រមាទ
ឲ្យខំសង្វាតរកទ្រព្យធន ៗ
ឲ្យរៀនច្បាប់សម្រាប់បវេណី
ឲ្យខំរកស៊ីកុំលួចប្លន់
ឲ្យសង្គ្រោះញាតិមានអាសន្ន
ឲ្យចេះអត់ធុនក្តីក្រៅក្រោធ ៗ
បើចេះត្រង់ណាឲ្យមាំមួន
ឲ្យចាំច្បាប់ក្បួនដកពបសោត
ឲ្យពេញជាប្រាជ្ញលោកយ៍កោត
បុកសោតឲ្យសមជាប្រាជ្ញប្រាយ ៗ
ឲ្យចាំទំនៀមទំនងព្រេង
ឲ្យចេះចាំបែងបទបរិយាយ
ឲ្យចេះពប់ព្រេងលានជិតឆ្ងាយ
ឲ្យផ្សាយមេត្តានឹងជនផង ៗ
ឲ្យស្គាល់ខ្ពស់ទាបដកពបទៅ
ឲ្យស្គាល់ប្រាជ្ញខ្មៅនៅរៀមច្បង
ឲ្យចងចាំចិត្តគិតខ្វាចហ្មត់

តទៅទំព័រទី ២៩

# និទានព្រះសុន្ទរសមុទ្ទត្ថេរ

## ពាក្យកាព្យ

៧ ដំណាលពីរឿងសុន្ទរ - សមុទ្រ.
កុលបុត្រសាវត្ថីល្បីឆើតឆាយ
សម្បូណ៌ដោយទ្រព្យច្រើនអម្បាល
សែសឹបកោដិ៍បាយសាយកេរ្តិ៍ឈ្មោះៗ
សាយ័ណ្ហសម័យបច្ឆាភត្ត
គាត់ឃើញពុទ្ធជនបរបំពោះ
វត្តជេតពនដោយស្ម័គ្រស្មោះ
កាន់អស់មាលាផ្កាកម្រង ៗ
មានចិត្តងឿងឆ្ងល់ខ្វល់សួរថា
លោកយាយលោកតាត្រាប់ត្រសង
ទៅកាន់ទីណាខ្ញុំទៅផង
ក្រែងត្រូវបំណងរបស់ខ្ញុំ . . . ៗ
ពួកជនប្រាប់ថាទៅស្តាប់ធម៌
ប្រសើរបវរល្អិតសុខុម

បើប្នេះកុមារទៅនឹងខ្ញុំ
ក្រែងចួបក្រមុំត្រូវចិន្តា ៗ
កុលបុត្រឮហើយអរសាទរ
ពាក់អាវស្លៀកខោយ៉ាងសង្ហា
ចូលទៅអង្គុយស្តាប់ទេសនា
ខាងក្រោយមហាជនទាំងឡាយ ៗ
ព្រះពុទ្ធទ្រង់ជ្រាបអជ្ឈាស្រ័យ
នៃកុលបុត្រថ្វីហើយបរិយាយ
អនុបុព្វីកថាធិប្បាយ
ឲ្យបាននឿយណាយចាកសង្ខារ ៗ
កុលបុត្រគិតថាការព្រហ្មច័ន្យ
ត្រូវលះប្រកាន់រូបអាត្មា
ប្នេះគួរចូលបួសក្នុងសាសនា
ង៉ាយលះរូបកាយាចោល ៗ

បួសស្រេចគ្រាប់ចរបិណ្ឌបាត
សង្វាតកាន់ក្រឹត្យពុំឲ្យឆ្ងាយ
ស្វះទុកប៉ុណ្ណោះជាខាងក្រោយ
និទានបណ្ដោយពីមាតា ។
បិតាកុលបុត្រសាវត្ថី
សង្រេងសង្រែបុត្រស្នេហា
គាត់ឃើញក្មេងៗលេងកំបា
គិតថាកូនយើងពុំធ្លាប់លេង ។
គ្រានោះឥត្ថីស្រីវេស្យា
លុះឃើញមាតា(១) យំសង្រេង
សង្រែសង្ស័យពេលស្ដាប់ក្មេង
វង្វេងក្មេងភ្លឹកនឹកបុត្រា ។
សួរថាលោកមីងយំរឿងអី?
ឬយំព្រោះក្ដីព្រាត់សង្សារ
សូមមីងប្រាប់ខ្ញុំឆាប់ ៗ ពី
ក្រែងការណ៍នោះក្មួយអាចជួយបាន ។
ញោមលោកប្រាប់ថាយំនឹកកូន
បណ្ដូលខ្ញឹមខ្លួនប្រាសពីប្រាណ

បួសបួសក្នុងសាសនព្រះទ្រង់ញាណ
ស្វែងធម៌ជាស្ពានទៅបរលោក ។
បើក្មួយមានប្រាជ្ញជួយរិះឈ្លាន
ទូន្មានឲ្យបានចេញអគ្យាគ
ឲ្យក្មួយជាម្ចាស់ទ្រព្យធនភោគ
ផ្សំផ្គុំនឹងលោកកូនមាតា ។
ក្សិណនោះឥត្ថីស្រីផ្កាមាស
ប្រដាប់តោះតោសសុទ្ធសឹងផ្កា
ប្រេងម្សៅទឹកអប់ជ្រួតកាយា
ក្លិនដូចក្រឹស្នាក្លិនខ្លឹមចន្ទន៍ ។
ស្លៀកហ៊ីប្រពាក់អាវតាមសម័យ
សក់អ៊ិតថ្មីៗ កាន់បង្ហាន់
សំដៅភដតីដោយរួសរាន់
បន្ទាន់ប្រញាប់ឆាប់ដាក់បាត្រ ។
ដល់មុខភិក្ខុលុតជង្គង់
លើកដៃជម្រង់ផ្គង់សំអាត
កាន់វែកចូកបាយដាក់ក្នុងបាត្រ
សង្វាតនិមន្តដោយវាចា ។
សូមបងឡើងទៅឯខាងលើ

(១) មាតាភិក្ខុ មិនមែនមាតានាងគណិកាទេ ។

ប្រាសាទចំទើរឆាន់អាហារ
ព្រោះនៅខាងក្រោមឮកុមារ
វាលេងកំឡាហុយធុលី ៗ
ខាងលើប្រាសាទស្អាតបញ្ចាំង
រលើបរលង់សព្វទិសទី
ឆាន់រួចសូមស្រង់ទឹកវារី
សឹមវិលកាន់ទីអាស្រមបទ ៗ
ភិក្ខុទទួលពាក្យវេស្សា
ដោយតុណ្ហីការដើម្បីកត្ត
គង់លើឧច្ចាសន៍ស្អាតម៉ត់ចត់
គាំងពត់ព្រះភ្នែនពែនបាទា ៗ
គ្រានោះឥត្ថីស្រីឆោមឆាយ
គាំងផ្តើមកែក្រាយបទមាយា
មារយាទស្ត្រីគ្រប់មាតិកា
សែសឹបមាត្រាដោយនិយម ៗ

១–. ញឹកញ៉ក់ញាំញើដើរកែក្រាយ
អែនអនពត់កាយបែបរម្យទំ
អៀនខ្មាសម្ញឹកម្ញ៉ក់ហាក់ស្ទើរយំ
ឡឹមឡុំឡឹកឡក់ទៅដេរ្ង ៗ ៗ

២–. កេះកៀវដៀវផុសទូវក្របក
ផ្កាត់ព្ចប៉ក ៗ ឡកលលេង
ឡេះឡោះម៉េះម៉ស់ហាក់ដូចក្មេង
ភាងភេទទន្ទេងលេងផ្លែផ្កា ៗ

៣–. លើកជើងជាន់ជើងព្ទ សូរក្តុង
ជាន់ក្តារម៉ឹងម៉ុងផុងកាយា
ឲ្យប្រុសឈរជិតង៉ាកក័ក្ត្រា
កិរិយាដូចជាបន្ទាន់ណាស់ ៗ

៤–. ឃើញឈើ ស្មៅវល្លិចាប់
បេះលេង
គូសគូរខ្វាត់ខ្វែងរូបផ្តេសផ្តាស
រូបប្រុសរូបស្រីរូបមាស
ពេញពាសប្រឹថពីទីដីដេញ ៗ

៥–. ចាប់លើកទារកឡើង ទៅលើ
ភ្លៅដាទំឃើមាត់ញាប់សេញ
ភ្នែកមៀមៀងមើលទៅប្រុសវិញ
ដូចចិត្តស្អប់ខ្ពាញ់បុត្រនោះណាស់ៗ

៦–. ដាក់បុះទារកឲ្យដើរដើ

តទៅទំព័រទី ៣០



## សមាគមប្រទេសកម្ពុជាមានប្រហែល២៨គឺ:

១— សាមគ្គីមិត្តខ្មែរកូសាំងស៊ីន ៣១-៧-១៩២៨,

២— សមគ្គីមិត្តនៃសិស្សចាស់នឹងមិត្តអនុវិទ្យាល័យ, វិទ្យាល័យស៊ីសុវត្ថិ: គ.ស. ១៩៣៥,

៣— សាមគ្គីមិត្តពួកមន្ត្រីគិលានសង្គ្រោះនៃប្រទេសកម្ពុជា : ១៤-៩-១៩៣៧,

៤— សង្គហបុគ្គលិកឥណ្ឌូចិននៃក្រុមស៊ីវិលយោធីនឹងឋានលេខាកម្ពុជរដ្ឋ: ៥-១-១៩៤៤,

៥— អសយដ្ឋានខេត្តខ្មែរ : ១៩៤១,

៦— សមាគមខ្មែរ-បារាំងនាវាចរ ១៩៤៦,

៧— សមាគមស៊ីវិលខ្មែរអប់រំសេដ្ឋកិច្ច: ១៩៤៦,

៨— សមាគមសហករណ៍ខ្មែរ : ២៥-១២-១៩៤៧,

៩— សមាគមនារីសហភាពបារាំង: ២៤-៥-១៩៤៨,

១០— សមាគមមន្ត្រីនៃរដ្ឋបាលខ្មែរ : ២៧-៧-១៩៤៨,

១១— សមាគមខេមរសហជីវិន: ១០-១០-១៩៤៨,

១២— សមាគមពួកតិកទិកកម្ពុជរដ្ឋ: ១៣-១០-១៩៤៨,

១៣— សមាគមខ្មែរ - បារាំង

អគ្គិសនីបាត់ដំបង . . . . ១៥-១០-១៩៤៨,

១៤— សង្គហបុគ្គលិកសិក្ខាធិការកម្ពុជរដ្ឋ: ២៥-១១-១៩៤៨,

១៥— សមាគមសិល្បកម្មខ្មែរ ១០-២-១៩៤៩,

១៦— ក្រុមសង្គហជាតិ: ឧសភា ១៩៤៩,

១៧— សមាគមមិត្តសាលាបាលី ៥-៨-១៩៤៩,

១៨— សមាគមយុវខេមរ: ២០-៨-១៩៤៩,

១៩— សមាគមគិលានសង្គ្រោះសម្រាប់ព្រះសង្ឃខ្មែរ: ២៨-១២-១៩៤៩,

២០— សមាគមកុមារសង្គ្រោះ: ១៩-៥-១៩៥០

២១— សាមគ្គីមិត្តបុគ្គលិកក្រុមរុក្ខា: ១៨-១១-១៩៥០

២២— សមាគមពួកមន្ត្រីខាងតុលាការ: ៣១-១-១៩៥២

២៣— សមាគមជាងមាសប្រាក់ខ្មែរ: ១៥-៣-១៩៥២

២៤— សមាគមឧបត្ថម្ភវត្តពិកទ្ធរណ៍ស្រ: ២៥-៥-១៩៥២

២៥— ពុទ្ធិកសមាគមពិភពលោក - មជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ ២៤-៧-១៩៥២

២៦— សមាគមមាតាបិតាកូនសិស្សនៃវិទ្យាល័យស៊ីសុវត្ថិ ២១-១០-១៩៥២

២៧— សមាគមនារីសង្គ្រោះ ២៨-១-១៩៥៤

២៨— សមាគមកម្មករសហជីវិន: ២៣-៣-១៩៥៤

ក្រៅពីនេះនៅមានសមាគមខាងពាណិជ្ជកម្មនិងកីឡាទៀតមិនទាន់បាន

តទៅទំព័រទី ៣១

# ប្រវត្តិក្មេងកំព្រា (តពីឆ្នាំ ១៩៥៥)

នាយវិន្ទោ មិនបានដឹងថា ក្នុងដំណើរដ៏ស្ងាត់កំបាំងរបស់ខ្លួននេះ មាននារីម្នាក់កំពុងតែលបតាមមើលផែនការរបស់ខ្លួនទេ

នារីដើរលប ៗ សន្សំម ៗ តាមក្រោយ ៗ ក្នុងដំណើរនេះនាងមិនបានចាប់ភ្លឹកថា តើឃ្លាតពីដម្រិចម្ងាយប៉ុន្មានមកហើយ ហើយនាងពុំដឹងទៀតថាព្រៃនេះជាលំនៅនៃសត្វសាហាវផង ដោយចិត្តរបស់នាង កំពុងតែស្ទុងទៅលើដំណើរដ៏ប្លែកនេះ

ខ្លាមួយធំកំពុងតែដើរតាមក្រោយនាង ទាន់តែជិតណាស់ហើយនៅប្រហែលជា១០០ម.ប៉ុណ្ណោះ ៗ យូរៗ នាងក្រឡេកមើលក្រោយម្តង ហើយក៏ពុំឃើញ មានអ្វីដែល នាំឲ្យនាងភ័យដែរ ឈរក្រឡេកមើលលើកនេះក៏ស្រាប់តែប្រទះសត្វសាហាវមួយយ៉ាងធំ ដែលនាំឲ្យនាងភ្ញាក់សំឡេងស្រែក យ៉ាងខ្លាំង ៗ

នាយវិន្ទោកំពុងតែ បន្តដំណើរទៅមុខដោយចិត្តក្រៀមក្រំ លុះឮសំរែកនេះភ្លាមក៏ស្ទុះរត់ដល់ម្ចាស់សំរែកតែម្តង ក្នុងពេលជាមួយគ្នានេះខ្លាក៏លោតសំដៅមករកអ្នកទៀត តែដោយនាយជាបុរសមួយរូប មានសេចក្តីក្លាហានទឹងអង់អាច ក៏ដកកាំបិតស្នៀតតយុទ្ធនឹងខ្លាក្នុងពេលនោះ ៗ ការតយុទ្ធនេះ គេត្រូវប្រើវេលាអស់ប្រហែលជា៣០នាទីទើប សម្រេចយកជ័យជំនះបាន ៗ

នារីកំពុងតែឈរញ័រ នៅទីដ៏គល់

ឈើមួយហាក់ដូចជាវិញ្ញាណ របស់នាងរត់ចោលរូបរាងកាយ បាត់ទៅហើយ, នាងឈរ ៗ នៅនឹងកន្លែងដរាបតែនាយវិន្ទាមានជ័យជំនះ ក៏នាងនៅតែពុំទាន់ដឹងខ្លួន, នាយដើរមកជិតហើយយកដៃមកអង្អែលខ្នងនាងហើយសួរថា៖ អូន ! អូន ! នារី ! ! ! នាងក៏ពុំមានសំឡេងអ្វីឆ្លើយតបមករកអ្នកវិញឡើយ ៗ នាយដឹងច្បាស់ថានេះមកពីនាងភ័យហួសហេតុ បានជាសន្លប់ទាំងឈរពុំដឹងខ្លួនយ៉ាងនេះ, នាយក៏លើកបីនាងដើរទៅមុខទៀត សំដៅទៅចំណាតដែលខ្លួនប៉ងនឹងមក ៗ

រូងភ្នំមួយតូចមានទំហំប្រហែលជា ១០ម.បួនជ្រុងនៅក្នុងរូងនោះគេឃើញមានវត្ថុប្លែក ៗ ជាច្រើន ដូចជាទៀន សម្រាប់ត្រងសំឡេង គ្រឿងចក្រសម្រាប់បង្កើតកម្លាំងអគ្គិសនី អាវុធនឹងគ្រាប់រំសេវ, ថ្នាំការពាររោគ នឹងប្រដាប់ប្រដាដទៃ ៗ ទៀតមានសំលៀកបំពាក់ ស្បែកសត្វគ្រប់បែប - យ៉ាងនឹងកន្លែងសម្រាប់សំណាក់អាស្រ័យជាដើម ៗ

នារីនាងពុំដឹងខ្លួនទៅឡើយទេ រាងកាយរបស់នាងកំពុងតែស្ដូកស្ដឹងនៅលើគ្រែមួយយ៉ាងស្អាត ដែលមាននាយវិន្ទាអង្គុយក្បែរផង ៗ ប្រហែលជា១០នាទីក្រោយមក ទើបគេឃើញភ្នែកនាងទាំងគូបើកសន្សឹមៗឡើង, កាលដែលនាងបើកភ្នែកដំបូង ក៏នឹកស្មានថានាងកំពុងតែគេងក្នុងជម្រំរបស់ខ្លួន តែគួរឲ្យនាងនឹកឆ្ងល់ដែរដោយដំណេករបស់នាងដូចជាមានសភាព ត្រជាក់ហើយសុខស្រួលផង ថែមទាំងឃើញនាយវិន្ទាមកអង្គុយនៅក្បែរនាងទៀត មានទាំងឈាមប្រឡាក់ពាសពេញខ្លួន ៗ នាង ក៏នឹកឃើញដល់សត្វខ្លាដែលស្ទុះមករកនាង ហើយក៏ដឹងដោយការ

ស្មានថា ខ្លួនបានរួចជីវិតដោយសារវិន្ទា ហើយនាយមានរបួសខ្លះដោយការតយុទ្ធនឹងខ្លា ។

កាលបើនាងនឹកឃើញហេតុយ៉ាងនេះហើយ ហាក់បីដូចជាស្លុតរន្ធត់ម្តងទៀត ក៏ស្ទុះមកឱបនាយដោយមិនមានបំណាង ហើយសួរទៅកាន់នាយថា

“ បង ហេតុម្តេចក៏បានជាខ្ញុំមកដល់កន្លែងនេះ ,,

“ ខ្ញុំនាំអូនមក ,, នាយឆ្លើយ

“ ម្តេចក៏ខ្ញុំមិនដឹងខ្លួន ,, នាងសួរ

“ កាលនោះអូនសន្លប់បាត់ស្មារតីទៅហើយ ,,

“ ចុះកន្លែងនេះនៅចម្ងាយប៉ុន្មានពីជម្រំយើង ,,

“ ប្រហែលជាមួយគីឡូម៉ែត្រប៉ុណ្ណោះទេ បើសិនជាវាស់តាមផ្លូវត្រង់ តែបើនិយាយតាមទំនងដែលបងដើរមកនេះ ប្រហែលជាបីគីឡូម៉ែត្រដោយផ្លូវបត់បែនច្រើន ,,

“ ចុះអ្នកជម្រំមាននរណាមួយបានដឹងកន្លែងនេះដែរ ,,

“ បងមិនដែលឲ្យជនណាមួយដឹងសោះឡើយ ព្រោះជាអាថ៌កំបាំងរបស់បង ,,

“ ពីមុនមកម្តេចក៏បងមិនឲ្យដឹងផង ,,

“ ដោយបងមិនទាន់មានសង្ឃឹម ,,

“ សង្ឃឹមអ្វី ? ,,

“ សង្ឃឹមថានឹងបាន . . . . បាន . . . ជា ,, នាយពោលហាក់មិនចេញ ដូចជាមានអ្វីមួយមកខ្ទប់មាត់អ្នកមិនឲ្យនិយាយតទៅទៀត ។

“ យ៉ាងដូចម្តេចបានជាបងមានអាការៈអឹមអៀមបែបនេះ ,, នាងសន្ទិញសួរ ប្រាប់អូនឲ្យត្រង់មើ ! កុំលាក់ កុំលាក់នឹងខ្ញុំឲ្យសោះ ! ណា៎ !!

“ សង្ឃឹមថានឹងផ្ញើ . . . ផ្ញើជីវិត

តទៅទំព័រទី៣៣

## បុណ្ណកុមារ (តពីឆ្នាំ ១៩៥៥)

# សង្គ្រាម

ដរាបណាដែលលោកនៅតែយល់ថា ភ្លើងនេះត្រូវតែយកភ្លើងទៅរំលត់ ដរាបនោះ លោកនៅតែត្រូវប្រើភ្លើងសម្រាប់រំលត់ភ្លើង ដែលជាការមិនខុសគ្នា ពីការដែលលោកប្រកាន់ថាសន្តិភាពនឹងកើតមានឡើង ដោយសារសង្គ្រាមនោះដែរ ។ កាលបើលោកទាំងមូលនៅតែយល់ដូច្នេះ គ្រប់រដ្ឋទាំងអស់ ត្រូវតែមានកងទ័ពសម្រាប់ស្វែងរកនូវសន្តិភាពបែបយល់សប្តិ ។ កាលបើរដ្ឋនិមួយ ៗ ស្វែងរកសន្តិភាពដោយកម្លាំងទាហានដូច្នេះ សង្គ្រាមរដ្ឋនឹងរដ្ឋក៏ឆេះឡើង កាលបើឃើញថា សង្គ្រាមរវាងរដ្ឋនឹងរដ្ឋឆេះឡើង ហើយយកសង្គ្រាមលោកទៅផ្ទុកផ្ទួនពីរលើសង្គ្រាមនោះទៅទៀត ដើម្បីនឹងដូរយកសន្តិភាពដែលលោកត្រូវការប្រាថ្នានោះ ទីបំផុតកូនសង្គ្រាមនោះក៏ឆេះរាលដាលឡើងទៅជាសង្គ្រាមលោក ។

កាលណាបើមានសង្គ្រាមកើតឡើងហើយ ពួកពលទាហានក៏ត្រូវគេបញ្ជាតប្រើឲ្យទៅស្លាប់ចោលកូន-ប្រពន្ធ ឪពុក-ម្តាយ-ញាតិសន្តាន-សាច់សារលោហិត -មិត្តភក្តិ ឯពួកសេដ្ឋសង្គ្រាម ក៏បានឆ្លៀតយកឱកាសនេះការកហុតឈាមប្រជាជន សាងមហាសុខសម្រាប់ខ្លួនលើគំនរមហាទុក្ខនៃប្រជាជន មិនតែប៉ុណ្ណោះ សង្គ្រាមអាចបំផ្លាញភោគទ្រព្យ និងជីវិតនៃមនុស្សធម្មតាសាមញ្ញ ឲ្យវិនាសហិន

ហោច ផុតក្តាយព្រាត់ប្រាសកូន ប្តីព្រាត់ប្រាសប្រពន្ធជាទីស្រឡាញ់ជាដើម គិត ៗ ទៅ ការដែលយល់ថាធ្វើសង្គ្រាមដូរយកសន្តិភាពនោះ ក៏មិនខុសគ្នាពីការនឹកឃើញស្រមៃ ឬយល់សប្តិប៉ុន្មាន ៗ

លុះដល់រដូវប្រាំង ផែនដីស្ងួតល្មមសមគួរដល់ការចាត់ក្បួនកងទ័ពធ្វើសង្គ្រាម កងទ័ពនៃទេវតីរនគរដែលបានហ៊ឹកហ៊ឺនមកអស់ពេលដ៏យូរក៏បានធ្វើបលនាចេញក្បួនទ័ពពីព្រះរាជធានី មានលោកមេទ័ព ទសយុទ្ធ ជាអ្នកកាន់អាជ្ញាសិទ្ធិបញ្ជាការ ជាមេទ័ពគំណាន់ព្រះនេត្រព្រះកាណើ ៗ សម្ទេងស្រែកហោកញ្ជ្រៀវ យកបុក្សដ៏យក៏លាន់ឮឡើងស្ទើរកក្រើកផែនដី ហើយកងទ័ពដែលស្រេកឃ្លាននូវសង្គ្រាម ក៏ចេញដើរឆ្ពោះទៅទិសខាងលិច ដែលជាផ្លូវទៅកាន់កល្យាណីបុរនគរតទៅ ៗ

ឯនាងកុសលាតាមមកជូនដំណើរបុណ្ណមាណពដល់មាត់ទ្វារក្រុង ព្រមទាំងផ្ដែផ្ដាំសព្វគ្រប់ ៗ បុណ្ណមាណពដូចជាស្រងាកចិត្ត ដោយសេចក្ដីអាឡោះអាល័យ ហើយទាញគ្រាប់ផ្កា៤គ្រាប់ ដែលពាក់ជាប់នៅកមកតាំងពីតូចៗ ហើយហូតយកពីរគ្រាប់ហុចទៅនាងកុសលា ព្រមទាំងនិយាយថា

"គ្រាប់ផ្កានេះ បងពាក់ជាប់នឹងខ្លួនមកតាំងពីតូចៗ ជារបស់ដែលគួរស្រឡាញ់ ព្រោះវាចាំដាស់តឿនបងជានិច្ចមិនឲ្យបងប្រហែសធ្វេសស្រវឹងនឹងវាសនារបស់បង គ្រាប់ផ្កានេះមាន៤គ្រាប់ សូមអូនទទួលយក២គ្រាប់ ហើយសូមយកទៅបងកទុក ដើម្បីជាគ្រឿងដាស់តឿនឲ្យអូននឹករលឹកដល់បង ឯ២គ្រាប់ទៀត បងក៏យកមកបងកបងទុកសម្រាប់ធ្វើឲ្យវាដាស់តឿនបងឲ្យនឹករលឹកដល់អូនគ្រប់ដង្ហើមចេញ-ចូលដែរ"

មិនមានអ្វីក្រៅពីសម្រេចយំខ្សឹកខ្សួលឆ្លើយតបទៅវិញ នៃនាងកុសលាឡើយ ។

កងទ័ពនៃទេវគិរីនគរបានធ្វើដំណើរឆ្ពោះទៅកាន់កល្យាណីបុរៈនគរ ជាច្រើនថ្ងៃ

ឥឡូវបានដល់ក្រុងនេះហើយ ក្រោយពីការបានប្រយុទ្ធបន្តិចបន្តួចនៅតាមផ្លូវចាប់ពីជាយដែនមក ហើយទីបំផុតកល្យាណីបុរៈនគរ ក៏ត្រូវសេនានុភាព នៃទេវគិរីនគរឡោមព័ទ្ធទុក ដោយមុឺនមាត់បិទផ្លូវជិតទាំងអស់ដែលគេស្មានមើលទៅថា នឹងបំណុះបុះចាញ់ ក្នុងពេលមិនយូរប៉ុន្មានទៀតនោះ ។

បុណ្ណមាណព បានសំដែងថ្វីដៃក្នុងការប្រយុទ្ធយ៉ាងក្លាហាន ធ្វើឲ្យទាហាននៃកល្យាណីបុរៈនគរ គោតញញើតជាខ្លាំង បើបុណ្ណមាណពទាញបង្ហៀសេះឲ្យឆាក់ទៅខាងណា ទាហាននៃពួកខ្មាំងក៏បែកទ័ពត្រង់នោះ ព្រោះមិនអាចធន់នឹងមុខដាវដ៏មុតនឹងការរហាស់របស់បុណ្ណមាណពបាន ។ ពួកខ្មាំងបានត្រូវរបួសស្លាប់ដូចគេកាយហើយក៏ចេះតែថយ ៗ ចូលព្រះនគរជានិច្ច តែការការពារបរិវេណទីក្រុងនោះក៏នៅតែរឹងប៉ឹងជានិច្ច ទើបកងទ័ពនៃទេវគិរីនគរមិនអាចនឹងវាយលុកយកទីក្រុងបានងាយ ៗ គ្រាន់តែកាយទ័ពឡោមព័ទ្ធទីក្រុង ហើយបញ្ជូនទាហានឲ្យទៅប្រយុទ្ធគ្នារាល់ថ្ងៃ នៅទីស្រឡះប៉ុណ្ណោះ ។

ព្រឹកនៃថ្ងៃមួយ ខណៈដែល បុណ្ណមាណពកំពុងនាំទាហានចេញទៅប្រយុទ្ធដូចសព្វដង ទ្វារនៃនគរក៏បានបើកឡើង ហើយកងទ័ពនៃកល្យាណីបុរៈនគរក៏បានស្ទុះចេញជាច្រើនពាស

តទៅទំព័រទី ៣៤

## ដំបូន្មាន (ត)

ឲ្យត្រង់ឲ្យត្រាប់ស្តាប់ធម្មា ៗ
ឲ្យមានមេត្តាប្រយ័ត្នទោស
ឲ្យមានសន្តោសលះលោភ
ឲ្យមានមេត្រីប្រណីគ្នា
ឲ្យជាឲ្យជាប់ខាងខន្តី ៗ
បើបងមានបុណ្យកុំពឹងបង
បើស្រីកន្លងកុំមេត្រី
លាភបាត់ផ្សិតឃោរព្រោះសំដី
បើស្រីចិត្តស្មើកុំឲ្យយក ៗ
បើចិត្តគិតស្អប់កុំឲ្យបាញ់
បើចិត្តស្រឡាញ់កុំឲ្យរក
បើស្រីប្តីលែងកុំឲ្យយក
ក្តីបងម្ចាស់មកកុំរកក្ស ៗ
បើរនាបបាក់គ្រាន់ទីងជួស
បើសំដីហួសបង់ទ្រព្យា
កុំកាចឲ្យគេស្អប់អាត្មា
កុំឲ្យអន់ការពូជពៅពង្ស ៗ
បើសិស្សគ្រូបីកុំភ្លើភ្លៀន
បើសេះល្អលឿនប្រងហាត្ថា

បើភ្លើទាហានពាលអាសា
ឲ្យខំគិតការឲ្យជាក់ស្បៀន ៗ
បើមួយហ៊ានសែនហ្វូងគាភ
មិនភ្លឺជ្រះថ្លាដូចព្រះចន្ទ
ដែកសុទ្ធផ្ទឹមម្តេចនឹងព្រះខាន់
ពិដោរខ្ទឹមបន្ទន់ជាប់ក្រឹស្នា ៗ
កុំឲ្យលេងច្រើនរាំច្រើនឈ្លោះ
កុំឲ្យលេះលោះរាំខូចការ
ស្រឡាញ់ពេញប្រាសពីគ្នា
បើស្អប់ត្រង់ណាជំពប់លើ ៗ
ពាក្យពីបុរាណទូន្មានមក
ចូរយកចិត្តចាំកុំភ្លេចភ្លើ
ចូរចាំពាក្យប្រុះគ្រប់អន្លើ
ផ្សិតខ្ញុំបានផ្ញើមកហើយហោង ៗ

ចាកដំបូន្មានបុរាណ

ភិក្ខុ សុំម — សុទ្ធ

បង្រៀនសាលាបាលីរង

វត្តវិហារចិទមាស ឃុំព្រែកស្តេងស្រុក
កណ្តាលស្ទឹង (កណ្តាល)

# និទានព្រះសុទ្ធរសមុទ្រគោរ (ត)

លើកដៃបង្គំ ១ ផ្ដេសផ្ដាស
វាយតិចវាយខ្លាំងប៉ះសាច់ខ្ទះ
ល្ងង់ណោមផ្ដេសផ្ដាសថាបេះបោះ ។

៧–. លេងនេះលេងនោះដោយខ្លួន
ឯង
ឬលេងប្រឡែងល្បែងឡេះឡោះ
ពន្យយពន្យល់ឆ្មើមេះម៉ស់
ឡេះឡោះលាក់លៀមក៏នានា ។

៨–. រើសនេះរើសនោះឲ្យក្មេងកាន់
ប្រវៃប្រច័ណ្ឌបុកពាលា
សុំបាយលោកខែឲ្យតុំឆា
ត្រីសាំងទឹកដាកែវពៅញុំា ។

៩–. ថៃថើបទារកសព្វកន្លែង
ថ្ពាល់គេថ្ពាល់ឯងខ្សឹតយ៉ាងមាំ
ញីញក់វិកវីទាល់សាំញ៉ាំ
ក្រហមថ្ពាល់ជាំសព្វគ្រា ។

១០–. ប្អូនកាលឆាកថ្ពាល់ឲ្យទារក
ផ្អាប់ផ្អឹកជិតនាសា
ក្មេងបណ្ដូលេះហោចសព្វហាត្ថា
ទារកប្រវាចាប់សុដន ។

១១–. បរិភោគបាយដោយខ្លួនឯង
កំពប់ពេញល្អងាសតិបទ
កាក់កាយគ្រាប់វាយច្រើនពេកពន់
ព្រោះដៃតូចតន់កៃវិតិសី ។

១២–. ហើយបែរប្រព្រាណាមកបញ្ចុក
បំណីបំណុកទារកខ្ចី
និយាយបូបាច់ពាក្យសំដី
ល្អង់ណោមកូនខ្ចីបបួនបទ ។

១៣ – ហុបនេះហុបនោះឲ្យទៅវា
ពណ៌នាបំពេរបៀងកំសត់
កន្សែងស្បូត្រសាយច្រៀងច្រើនបទ
ផ្ញុំបុំនឹងមាត់ស្ងាត់បំណាន ។

១៤ – ចាប់នេះឈានោះទាញ
កញ្ចាក់
ហាក់លោហាក់ហាក់ ហើរហោះហាន
ជន្ទូជន្ទេញដណ្ដើមដាន
ញោច្រានដៃជើងខ្លួនប្រាណក្មេង ។

១៥ — ល្ងើត្រាប់សំឡេងថាហៃគេ!
ប៉ុណ្ណឹងទេគេបងល្ងើលេង
ល្ងើយល្ងើសើចឬល្ងើក្លង
ម្តងគេងម្តងគគោមទារក ៗ

១៦ — . ពេលខ្លះបញ្ចេញទូរស
ម្សេង
ស្រែកឮក្តែង ៗ ថាហាក ៗ!
បើគេបែរមើលបែបទាល់ប្រក
តែនៅម៉ឹកម៉ក់ដំណើរល្ងន់ ៗ

១៧ — . . ពេលខ្លះនិយាយបែប
ពាក្យខ្សុប
ព្រោះត្រូវបំណុចស្រស់តូបតន់
ល្ងើបុកនឹងជឹងគ្រប់ល័ក្ខខ័ណ្ឌ
បែបដូចប្រប័ណ្ឌអ្នកណាម្នាក់ ៗ

១៨ — ត្រូវហើយ! ហ្នឹងហើយ -
គោលច្បាស់ ៗ
បំណកស់អក្សរគ្រប់វិតវគ្គ
មិនបានរៀនទេបេះចាប់ថ្នាក់
ល្ងើហាក់ឪបួបចេញថ្ងូ ៗ (នៅមានត)

# បកិណ្ណក (ត)

ស្រង់យកមកចុះ ៗ បើគេពត៌មាន បានសព្វគ្រប់វេលាណា នឹងចុះជូនជា ខាងក្រោយពុំខាន ៗ

× × ×

អ្នកមានសញ្ញាបត្រមហាបរិយេត្តិ ឧត្តមវិជ្ជាអាចប្រឡងយកឋានៈជាអ្នក និពន្ធតែងសេចក្តី ៗ នេះជាហេតុមួយ សឲ្យឃើញថា ការលើកដំកើងអក្សរ សាស្ត្រជាតិកំពេះតែបំរើនឡើងជាលំ ដាប់ ៗ

ចុះបើយើងគិតពីបៀវត្សន៍ឋានៈវិញ តើយ៉ាងណា ត្រូវទទួលតាមបៀវត្ស ក្របខណ្ឌអ្នកពជការជាន់ខ្ពស់ឬជាន់ កណ្តាល ? បំពោះអ្នកនិពន្ធភាសាបរ ទេសវិញ គេបានទទួលបៀវត្សព្រម ទាំងឋានៈជាអ្នកពជការជាន់ខ្ពស់ ៗ លុះគេងាកមើលមកអ្នកនិពន្ធតែងសេច ក្តីភាសាជាតិវិញ ឃើញមានបៀវត្ស

តាមអ្នករាជការក្របខណ្ឌជាន់កណ្ដាល តែឋានៈជាន់ខ្ពស់ដូចគ្នាឬ ?

ថា៖ សាស្ត្រាចារ្យសម្រាប់ពុទ្ធិកវិទ្យាល័យនឹង សាស្ត្រាចារ្យសម្រាប់វិទ្យាល័យនានា ក៏គង់មាន ការផ្សេងដោយបៀវត្សរ៍ដែរ ! ចំពោះឋានៈវិញ ប្រហែលជាខ្ពស់ដូចគ្នាក៏ពុំដឹង ?

ចំពោះបព្វជិតជា សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ គេថាលោកមិនត្រូវការចាយវាយរូបិយវត្ថុ មិនបាច់ប្រគេនលោកឲ្យច្រើនទេ ព្រោះបង្អាន់កុដិអារាមមានឧបាសកគេទំនុកបំរុងហើយ ៗ ខ្ញុំថាបើដូចនេះមែនកុំប្រគេនលោក តែម្ដងទៅល្អជាង ព្រោះរូបិយវត្ថុតិចក៏ដូចជាច្រើន បើប្រគេនក៏គួរតែលៃលកឲ្យសមនឹងឋានៈ ៗ សាស្ត្រាចារ្យជាគ្រហស្ថទៀតសោត ក៏មានបៀវត្សរ៍ចាញ់ប្រៀប នឹងសាស្ត្រាចារ្យនៃវិទ្យាល័យដទៃទៀតច្រើនណាស់ បើមិនឲ្យបៀវត្សរ៍សមនឹងឋានៈទេ ក៏យើងបញ្ហាឋានៈស្មើនឹងប្រាក់ខែទៅ ទើបយុត្តិធម៌ ៗ ថាបព្វជិតលោកមានពួកជនជាអ្នកឧបត្ថម្ភ ចុះគ្រហស្ថដូចគ្នា ម្ដេចក៏ផ្សេងគ្នាដែរ ?

ទាំងគ្រហស្ថ ទាំងបព្វជិតត្រូវការរូបិយវត្ថុដូចគ្នា តែថាគ្រហស្ថគេចាយវាយសម្រាប់គ្រួសារ ចំពោះព្រះសង្ឃលោកប្រើប្រាស់លើបច្ច័យបួននឹង សាធារណៈប្រយោជន៍ ដែលមានវេយ្យាវច្ចជាអ្នកទទួលចាត់ចែងការប្រើប្រាស់បែបនេះហើយដែលយើងជឿជាក់ថា មិនប៉ះផ្លូវវិន័យ ៗ ព្រោះបើភិក្ខុមិនមានត្រេកអរលើរូបិយវត្ថុនោះតើ អាបត្តិមកពីណា ?

គេសួរថា៖ ម្ដេចក៏លោកមិនត្រេកអរ បើចាយវាយរូបិយវត្ថុទៅហើយនោះ ?

មែន ! តែចំពោះលើបច្ច័យបួន ចុះ

បច្ច័យទាំងប្អូននោះ អាចបំប៉នកិលេសបានដែរ? នឹងប្រយោជន៍សាធារណ៍មានធ្វើឲ្យលោកស្រើបស្រាល ដោយកាមគុណចំពោះប្រយោជន៍នោះដែរ?

ទេ! បច្ច័យនឹងមិនបំប៉នកិលេសឡើយ ហើយសាធារណៈប្រយោជន៍ក៏មិនបង្កើតកាមគុណដែរ! ព្រោះជារបស់សង្ឃឬសាធារណៈ ជនទូទៅក្នុងសាសនាទៅហើយ!

បើដូចនេះគួរឲ្យថានៈនឹងបៀវត្សសក្តិសមគ្នា ទោះបីខាងណាក៏ដោយ ទើបឈ្មោះថា នឹងមានយុត្តិធម៌នឹងជួយលើកដំកើងសាសនាផង

ប៉ុណ្ណោះ គ្រាន់តែជាកិច្ចជូនយោបល់

---

## ប្រវត្តិក្មេងកំព្រា (ត)

...លើអូន...!” នាយឆ្លើយ

“នុ! ហេតុប៉ុណ្ណឹងបងនិយាយប្រាប់អូនមិនបាន! មានតែមិនទុកចិត្តខ្ញុំ! ចុះហេតុម្តេចបានជាបងលួចមកទីនេះតែម្នាក់ឯងដូច្នេះ” នាងសួរទៀត

“បងមកនេះ មិនមានហេតុអ្វីសំខាន់ទេ” នាយឆ្លើយ

“បើគ្មានហេតុម្តេចបានជាបងមក”

“អូន! ណ្ហើយចុះ អូនមិនបាច់សួរបងច្រើនពេកទេ, សម្រាប់ជីវិតរបស់បងក្នុងពេលថ្មីៗនេះ គឺបងមិនអាចរស់នៅជាមួយនឹងអូនបានឡើយ ហើយថែមទាំងមិនអាចឃើញមុខអូនតទៅទៀតបានផងៗ អូនដឹងខ្លួនទេ! ថាបងស្រឡាញ់អូន! ហើយបងដឹងច្បាស់ទៀតថា អូនមិនមានមេត្រីលើបងសូម្បីប៉ុនសរសៃសក់ឡើយ ហើយបែរជាទៅស្រឡាញ់សំណាង ជាកូនចិញ្ចឹមរបស់ឪពុកអូនឯងវិញ ដែលគេស្រឡាញ់អូនឯងដូចប្អូនបង្កើតនោះៗ

(នៅមានត)

## បុណ្ណកុមារ (ត)

ពេញ មក ធ្វើការ ប្រយុទ្ធ តស៊ូជាខ្លាំង បុណ្ណមាណព បានចោលភ្នែកទៅ ឃើញនាយទាហានដែលលើកទ័ពមក នោះជិះសេះសុទ្ធ បែបភាពអង់អាច ជានាយទាហានមុខថ្មី ដែលខ្លួនមិន ដែលបានឃើញមកពីប៉ុន្មានថ្ងៃមុននេះ សោះ តែថ្វីដៃខាងកាប់ដាវនៃនាយ ទាហានថ្មីជិះសេះសនោះ ក៏ពូកែ ហើយរហ័សខ្លាំងណាស់ដែរ ។ ទាហាននៃទេវគិរីនគរ មិនអាចនឹងទប់ទល់បាន ទើបបែកខ្ញែកគ្នាខ្ចាត់ខ្ចាយ អស់មិនហ៊ានចូលជិត បុណ្ណមាណព ឃើញដូច្នោះ ក៏ញាក់សេះឲ្យបោល សំដៅទៅរកនាយទាហាននោះ លុះ ចូលទៅជិតមែនទែន ក៏សង្កេតឃើញ ថា នាយហាននោះមានលក្ខណៈដំណើរទំនងបែបភាពដូចខ្លួនឥតខ្ចោះ តែជាដូចជាមានវ័យក្មេងជាងខ្លួនបន្តិច ខណៈដែលបុណ្ណមាណព កំពុងតែរំពិនិត្យសង្កេតមើលផងគិតផងដូច្នេះ សន្ទុះ ល្បឿនសេះដែលខ្លួនជិះ ក៏បានបោល សំដៅចូលទៅក្នុងរង្វង់ឡោមទ័ព មាន ទម្រង់ដូចជាស្នែងក្របីរបស់ពួកខ្មាំង ហើយនាយទាហានដ៏មានថ្វីដៃទាំងពីរ នាក់ក៏បានជួបមុខតទល់គ្នា ។

នាយទាហាននៃកល្យាណីបុរៈនគរដែលជិះសេះសុទ្ធដូចជាស្លុតចិត្ត បន្តិចបន្តួច ក្នុងកាលដែលបានឃើញ មុខបុណ្ណមាណព តែក៏បេះតែញាក់ សេះបួលសម្រុកប្រយុទ្ធយ៉ាងចំណានៗ ប្រែស! ប្រែស! ស្នូរដាវនឹងដាវប៉ះ ទង្គិចគ្នា! សេះសនឹងសេះខ្មៅក៏បេះ តែបន្ទន់ខ្លួននឹងស្ទុះបុះឡើងៗ តាមទំនង ស្ទៀតវៀងខ្លួនយ៉ាងក្លាហាន នឹងស្ទាត់ ជំនាញ ទាហាននៃកល្យាណីបុរៈនគរ ក៏ឡោមព័ទ្ធជុំវិញទាំងអស់ ។

ថ្វីដៃនៃនាយទាហានទាំងពីរនាក់

ប្រហែលៗគ្នា ខាងណាក៏នៅមិនទាន់ភ្ញាក់ស្មៀតនៅឡើយ សេះទាំងពីរត្រូវធ្វើការជាទមុន ព្រោះត្រូវគេបនឹងស្ទុះចុះឡើង ទាល់តែបែកញើសសើមពេញខ្លួន សូរជាវបេះតែលាន់ឮជានិច្ចមិនដាច់សូរ ព្រោះម្ចាស់ទាំងពីរបេះតែគ្រវីគ្រវាត់ ខ្ទប់ចុះខ្ទប់ឡើងយ៉ាងរហាស់ស្ទើរតែមើលមិនទាន់ ។

ខណៈដែលនាយទាហាននៃគល្យាណីបុរៈនគរញាក់សេះសម្រុកចូលប្រកៀកជិតកាប់ផ្ដាច់ទៅ បុណ្ណមាណពនាយទាហានដ៏អង់អាចនៃទេវគិរីនគរ ក៏ជ្រោងរងដាប់ ហើយទាញដាវដកមកវិញយ៉ាងរហាស់ កាប់តម្រង់ទៅត្រង់កនៃនាយទាហានគល្យាណីបុរៈនគរភ្លាម តែគេក៏រងដាប់ដែរ បុណ្ណមាណពត្រឡៀសដាវចាក់បន្ថែមលើនោះទៅ-ទៀតតម្រង់ពោះនាយទាហាននៃនល្យា-ណីបុរៈនគរគេក៏ផងតខ្លួនទៅខាងក្រោយទាន់ តែក៏គង់មិនផុតស្រឡះពីចុងដាវនៃបុណ្ណមាណពឡើយ ពេលដែលបុណ្ណមាណព លើកដាវប្រុងនឹងកាប់បន្ថែមម្ដងទៀតនោះ ចុងដាវក៏ទាក់នឹងអាវនៃនាយទាហាននៃគល្យាណីបុរៈ-នគរ ហើយធ្វើឲ្យរហែកអាវបន្តិចទៅបំក្រោមកពីមុខ ខណៈនុះឯង បុណ្ណ-មាណព ក៏មើលឃើញគ្រាប់ផ្គាំ៤គ្រាប់ដែលខ្ទាំងពាក់នៅក ។

បុណ្ណមាណពស្រឡាំងកាំង នឹងធ្ងល់ជាទីបំផុត ដែលខ្ទាំងមានគ្រាប់ផ្គាំ៤គ្រាប់ដូចខ្លួនដែរនោះ ឯនាយទាហាននៃគល្យាណីបុរៈនគរធ្វើកលជាថយបញ្ឆោតឲ្យបុណ្ណមាណពដេញតាមទៅ ។

បុណ្ណមាណពក៏ដេញតាមក្រោយទៅ ចិត្តដែលរវល់គិតតែពីការប្រញាប់ដើម្បីដេញតាមខ្ទាំងនោះ ធ្វើឲ្យម្ចាស់គឺបុណ្ណមាណពមិនបានប្រុងខ្លួនសោះ

ឡើយ ទាល់តែសេះទៅទាក់ជើងនឹងអន្ទាក់នៃខ្មាំងដួលព្រួស ក្រោកលែងរួច ហើយគ្រវាត់ បុណ្ណមាណព ចោលទៅយ៉ាងឆ្ងាយ ដោយសារការធ្លាក់ពីលើខ្នងសេះឈឺខ្លាំងពេកបុណ្ណមាណពស្ទើរតែនឹងសន្លប់បាត់ស្មារតី តែលុះចំប្រវេប្រវ៉ាក្រោកតេសតាសឡើង ក៏ត្រូវពួកទាហានខ្មាំងចោមរោមចាប់ចងបាន ហើយបណ្ដើរចូលទៅក្នុងទ្វារនៃនគរបាត់ទៅ ។

បុណ្ណមាណពត្រូវគេនាំខ្លួនចូលទៅក្នុងព្រះរាជវាំងដើម្បីបង្ហាញខ្លួនដល់ព្រះបាទសត្យរាជ ព្រះរាជានៃកល្យាណីបុរៈនគរយ៉ាងរហាស់ ៗ បុណ្ណមាណពងើបមុខឡើង ក្រឡេកមើលទៅឃើញនាយទាហានដែលប្រយុទ្ធគ្នានឹងខ្លួនអម្បាញ់មិញនេះឈរនៅជិតព្រះរាជបល្ល័ង្ក ព្រមទាំងនាយទាហានឯទៀតជាច្រើនអមនៅខាងក្រោយ ។

“ ល្អហើយ ! សត្យាទរៈកូនសម្លាញ់ ! „ ព្រះរាជាទ្រង់មានបន្ទូលទៅកាន់នាយទាហានដែលប្រយុទ្ធគ្នានឹងបុណ្ណមាណពអម្បាញ់មិញនេះ “ ចេញច្បាំងតែម្ដងក៏អាចចាប់យកខ្លួននាយទាហានដែលក្លាហានអង់អាចរបស់ពួកខ្មាំងមកទាំងរស់បាន ទាល់តែប៉ុណ្ណឹងទើបមិនបំបង់បាយ ដែលឪពុកចិញ្ចឹមមក ហើយសមជាកូនឪពុកមែន „

“ សូមព្រះបិតាកុំអាលអរពេក „ នាយទាហានទូល „ ខ្មាំងមានកម្លាំងខ្លាំងណាស់ គ្រាន់តែចាប់នាយបានមកម្នាក់នោះ នៅមិនទាន់ឈ្នះជាឈ្នះនៅឡើយទេ „

(នៅមានត)

រោងពុម្ព វិរិយ៍
នៅខាងត្បូងផ្សារអូរឫស្សី
ភ្នំពេញ